# ស្ថានភាពអតិផរណានៅខែកុម្ភៈ ឆ្នាំ២០១៨

## ក/ អតិផរណាក្នុងប្រទេស

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញក្នុងខែកុម្ភៈ ឆ្នាំ២០១៨ បានកើនឡើងក្នុងអត្រា **០,៤%** ធៀបនឹងខែមុន និង **២,៣%** បើធៀបនឹង១២ខែមុន។

ក្នុងខែកុម្ភៈនេះ សន្ទស្សន៍ថ្លៃក្រុមទំនិញមួយចំនួនមានការកើនឡើងគួរឱ្យកត់សម្គាល់ធៀបនឹងខែមករាកន្លងទៅ ក្នុងនោះមានដូចជា សន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង, ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់, ភោជនីយដ្ឋាន, និងកំសាន្តនិងវប្បធម៌។ តាមការសង្កេត ថ្លៃផ្លែឈើស្រស់កើន ១,៨%, សាច់មាន់កើន ១,១%, សាច់គោបានកើន ០,៧% និងសាច់ជ្រូកកើន ០,៣% ដែលការកើនឡើងថ្លៃនេះដោយសារតម្រូវការប្រើប្រាស់ខ្ពស់ក្នុងអំឡុងពេលប្រារព្ធពិធីចូលឆ្នាំចិន។

បើធៀបនឹងខែដូចគ្នាឆ្នាំមុន សន្ទស្សន៍ថ្លៃក្រុមទំនិញមួយចំនួននៅតែបន្តកើនឡើងដូចជាសន្ទស្សន៍ថ្លៃភោជនីយដ្ឋាន, ការដឹកជញ្ជូន, អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង និងផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត។ តាមការសង្កេត ក្រុមទំនិញជាប្រភេទអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹងបានកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងនោះ ថ្លៃត្រីស្រស់បានកើនឡើង ៤,៤%, សាច់គោកើន ២,៨%, អង្ករកើន ២,១%, ផ្លែឈើស្រស់កើន ០,៩%, ថ្លៃសាច់មាន់កើន ០,៥% និងថ្លៃសាច់ជ្រូកកើន ០,៣% ប៉ុន្តែអត្រាកំណើននេះគឺមានកម្រិតទាបជាងអត្រាកំណើននៅក្នុងខែកុម្ភៈ ឆ្នាំ២០១៧កន្លងទៅ។ ចំណែកឯ ថ្លៃប្រេងសាំងធម្មតាកើន ៦,៧%, ប្រេងម៉ាស៊ូតកើន ៥,៧% និងឧស្ម័នកើន ៧,៦% ស្របពេលនឹងការកើនឡើងនៃថ្លៃប្រេងឆៅលើទីផ្សារអន្តរជាតិផងដែរ។

| តារាង ១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម (%) | | |
|---|---|---|
| | **ធៀបនឹងខែមុន** | **ធៀបនឹង១ឆ្នាំមុន** |
| **មុខទំនិញគ្រប់មុខ** | **+០,៤** | **+២,៣** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | +០,៦ | +២,១ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | +០,៤ | +០,៦ |
| ៣-សម្លៀកបំពាក់និងស្បែកជើង | -០,២ | +១,២ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន | ០,០ | +១,៧ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ | +០,១ | +០,៥ |
| ៦-សុខាភិបាល | +០,៣ | +១,៤ |
| ៧-ការដឹកជញ្ជូន | -០,២ | +២,៩ |
| ៨-គមនាគមន៍ | +០,៣ | -០,៩ |
| ៩-ការកំសាន្ត និងវប្បធម៌ | +០,៤ | -១,០ |
| ១០-ការសិក្សា | ០,០ | -០,៧ |
| ១១-ភោជនីយដ្ឋាន | +០,៥ | +៦,៩ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | +០,២ | +៣,៣ |

| តារាង ១ ÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបខែមុន (%) | | | ធៀបនឹងឆ្នាំមុន (%) | | |
| | ២០១៧ | ២០១៨ | | ២០១៧ | ២០១៨ | |
| | ធ្នូ | មករា | កុម្ភៈ | ធ្នូ | មករា | កុម្ភៈ |
| អង្ករ | +០,១ | +០,១ | +០,២ | +១,៦ | +២,៣ | +២,១ |
| សាច់គោ | +០,៨ | -០,៥ | +០,៧ | +៣,០ | +២,២ | +២,៨ |
| សាច់មាន់ | -០,៦ | -០,៣ | +១,១ | +០,៣ | -០,៩ | +០,៥ |
| សាច់ទា | +០,៣ | -០,១ | -០,២ | +០,៦ | +០,៤ | +០,៩ |
| សាច់ជ្រូក | -០,៦ | +០,៦ | +០,៣ | -០,៣ | -០,២ | +០,៣ |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | ០,០ | -០,១ | +០,៣ | +៤,៥ | +៤,៣ | +៤,១ |
| ក្នុងនោះត្រីស្រស់ | ០,០ | -០,២ | +០,៣ | +៤,៩ | +៤,៦ | +៤,៤ |
| ផ្លែឈើ | +០,៨ | -០,៥ | +១,៧ | +១,០ | -០,១ | +១,៧ |
| ផ្លែឈើស្រស់ | +១,០ | -០,៥ | +១,៨ | +០,៣ | -០,៨ | +០,៩ |
| បន្លែ | +០,៦ | -០,៣ | +០,៣ | -០,៩ | -១,៤ | -០,៥ |
| បន្លែជាស្លឹក | +១,៦ | -១,២ | +០,១ | -០,៧ | -១,៧ | -០,៩ |
| បន្លែជាផ្លែ | -០,១ | +១,៤ | +០,៧ | -៤,០ | -៣,៨ | -១,៦ |

## ១/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង ៣÷ អតិផរណាចុងឆ្នាំ (Year on Year) គិតជា % | | | | |
|---|---|---|---|---|
| ប្រទេស | ២០១៧ | | ២០១៨ | |
| | មករា | កុម្ភៈ | មករា | កុម្ភៈ |
| ប្រទេសកម្ពុជា | 4.4 | 4.0 | 2.0 | 2.3 |
| ប្រទេសវៀតណាម | 5.2 | 5.0 | 2.7 | 3.2 |
| ប្រទេសថៃ | 1.6 | 1.4 | 0.68 | 0.42 |
| ប្រទេសម៉ាឡេស៊ី | 3.2 | 4.5 | 2.7 | 1.4 |
| ប្រទេសឥណ្ឌូនេស៊ី | 3.5 | 3.8 | 3.3 | 3.2 |
| ប្រទេសហ្វីលីពីន | 2.7 | 3.3 | 4.0 | 3.9 |
| ប្រទេសចិន | 2.5 | 0.8 | 1.5 | 2.9 |
| ប្រទេសកូរ៉េខាងត្បូង | 2.0 | 1.9 | 1.0 | 1.4 |
| ប្រទេសជប៉ុន | 0.4 | 0.3 | 1.4 | 1.5 |

ប្រភពទិន្នន័យ

(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)

(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

<u>**កំណត់សម្គាល់**</u>

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបតំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

***រៀបចំនិងធ្វើចំណោលដោយ***

***នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច***

***អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ ០២៣ ៤២៧ ៩១៣, ០៧៧ ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*

*កំណត់សម្គាល់÷*

*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។*

*ការផ្សព្វផ្សាយនេះមិនស្តែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*